## ការប្រគល់ខ្លួន (surrender)

ការប្រគល់ខ្លួន ជាការប្រគល់នូវបុគ្គលណាម្នាក់ដោយរដ្ឋ ឬអង្គភាព ទៅដល់តុលាការ ព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ច។ ការប្រគល់ខ្លួននេះ មានចែងក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិមាត្រា ១០២ (International Criminal Court: ICC)។ ទង្វើនេះ ខុសគ្នាខ្លះនឹងបត្យាប័ន (extradition) ដែលជាការបញ្ជូនបុគ្គលរវាងរដ្ឋ និងរដ្ឋ។ ទោះបីជាយ៉ាងណាក្តី ក៏មានលក្ខខ័ណ្ឌ និងឧបសគ្គស្រដៀងគ្នា។ នេះដូចជា ការមិនប្រគល់ជនដែលមានសញ្ជាតិ និងគោលការណ៍ពិសេស (rule of specialty)។ ការប្រើប្រាស់គោលការណ៍នេះ មិនទំនងជាតឹងរឹងទេ ដោយសារ ទម្ងន់នៃភាពមិនចង់ឲ្យមាននិទ្ទណ្ឌភាពដល់ទង្វើល្មើសក្រោមច្បាប់អន្តរជាតិ។

ការប្រគល់ខ្លួននេះ ក៏មានបញ្ហាប្រឈមនៅ ICC អនុលោមតាមមាត្រា៩៨ នៃ លក្ខន្តិកៈដែលអាចត្រូវបានបកស្រាយមិនបញ្ជូនខ្លួនជនទីបី ទៅ ICC ដោយសារជននោះ មានអភ័យឯកសិទ្ធិ (រដ្ឋនោះ មិនមែនជាភាគីនៃលក្ខន្តិកៈ)។ ផ្អែកតាមមូលហេតុនេះ សហរដ្ឋអាមេរិក ដែលមិនមែនជាភាគីនៃលក្ខន្តិកៈ បានចុះកិច្ចព្រមព្រៀងជាង ១០០ ជាមួយរដ្ឋជាច្រើន ក្នុងគោលបំណង មិនឲ្យរដ្ឋជាភាគី បញ្ជូនជនជាតិអាមេរិកទៅ ICC (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p.527។

**ខ្លឹមសារបន្ថែម៖** សហរដ្ឋអាមេរិក ក៏បានចុះកិច្ចព្រមព្រៀងទ្វេភាគី ដែរជាមួយព្រះរាជាណាចក្រកម្ពុជា (bilateral agreement between USA and Cambodia)។